**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## អាករលើតម្លៃបន្ថែម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៧ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ._**

អនុក្រឹត្យនេះ មានគោលបំណងកំណត់នូវវិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលអាករលើតម្លៃបន្ថែម។

**មាត្រា២ ._**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះការផ្គត់ផ្គង់ជាប់អាករនូវទំនិញឬសេវានៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ ._**

សម្រាប់គោលដៅនៃអនុក្រឹត្យនេះ៖

១- ទំនិញ សំដៅដល់ ទ្រព្យរូបីក្រៅពីដីធ្លីនិងប្រាក់កាស។

២-សេវា សំដៅដល់ ការផ្តល់អ្វីមួយដែលមានតម្លៃក្រៅពីទំនិញ ដីធ្លី និងប្រាក់កាស។

៣-ការផ្គត់ផ្គង់ទំនិញ សំដៅដល់ ការផ្ទេរសិទ្ធិប្រើប្រាស់ ឬសិទ្ធិចាត់ចែងក្នុងឋានៈជាម្ចាស់កម្មសិទ្ធិទំនិញទោះបីមានសំណងឬគ្មានសំណងក្តី។ ការផ្គត់ផ្គង់សេវាបន្ទាប់បន្សំដែលទាក់ទិននឹងការផ្គត់ផ្គង់ទំនិញ ត្រូវចាត់ទុកដូចជាការផ្គត់ផ្គង់ទំនិញ។

៤- ការផ្គត់ផ្គង់សេវា សំដៅដល់ ការផ្គត់ផ្គង់ដែលមិនមែនជាការផ្គត់ផ្គង់ទំនិញ ដីធ្លី ឬប្រាក់កាសដែលធ្វើឡើងដើម្បីបានទទួលសំណងឬគ្មានសំណងក្តី។ ការផ្គត់ផ្គង់ទំនិញបន្ទាប់បន្សំដែលទាក់ទិននឹងការផ្គត់ផ្គង់សេវា ត្រូវចាត់ទុកដូចជាការផ្គត់ផ្គង់សេវា។

៥- បុគ្គល សំដៅដល់ បុគ្គល ឬក្រុមបុគ្គលដែលធ្វើអាជីវកម្ម និងបុគ្គលណាមួយទៀតដែលទាក់ទិនជាមួយបុគ្គលនោះ។

៦- បុគ្គលជាប់អាករ សំដៅដល់ បុគ្គលដែលត្រូវជាប់ពន្ធតាមរបបស្វ័យប្រកាសហើយធ្វើការផ្គត់ផ្គង់ជាប់អាករដូចមានចែងក្នុងមាត្រា៥៩ នៃច្បាប់ស្តីពីសារពើពន្ធ។ សម្រាប់គោលដៅនៃអនុក្រឹត្យនេះ បុគ្គលអនិវាសនជន ដែលផ្គត់ផ្គង់ទំនិញឌីជីថលឬសេវាឌីជីថលមកក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់ទុកជាបុគ្គលជាប់អាករ។

៧- ផលរបរជាប់អាករ សំដៅដល់ ផលរបរដែលបានមកពីការផ្គត់ផ្គង់ជាប់អាករនូវទំនិញឬសេវា។

៨- ទាក់ទិន ចំពោះបុគ្គលណាមួយ មានន័យថា៖

- ក- បុគ្គលណាមួយដែលមានកម្មសិទ្ធិចាប់ពី ២០ (ម្ភៃ) ភាគរយ ឡើងទៅលើតម្លៃឬសិទ្ធិបោះឆ្នោតនៃភាគកម្មនៅក្នុងដើមទុនផ្ទាល់នៃបុគ្គលដែលលើកយកមកពិចារណា។
- ខ- មានការគ្រប់គ្រងរួមគ្នា ឬមាននាយករួមគ្នាជាមួយបុគ្គល។
- គ- ជាសមាជិកគ្រួសារ ឬជាសហព័ទ្ធ ឬជាសមាជិកក្រុមគ្រួសារនៃសហព័ទ្ធរបស់បុគ្គល។
- ឃ-បានទិញចាប់ពី ៣០ (សាមសិប) ភាគរយ ឡើងទៅនៃធាតុចេញសរុបរបស់បុគ្គលក្នុងរយៈពេល ៣ខែបន្តបន្ទាប់។

៩- ទំនិញឌីជីថល សំដៅដល់ ទំនិញអរូបីដែលត្រូវបានបញ្ជាទិញ ផ្គត់ផ្គង់ និងបញ្ជូនទាំងស្រុងតាមប្រព័ន្ធអេឡិចត្រូនិក។

១០-សេវាឌីជីថល សំដៅដល់ សេវាដែលត្រូវបានធ្វើប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិក។

១១-ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក សំដៅដល់ សកម្មភាពទិញ លក់ ជួល ផ្លាស់ប្តូរទំនិញឬសេវា រួមទាំងសកម្មភាពពាណិជ្ជកម្មនិងរដ្ឋប្បវេណី ព្រមទាំងសកម្មភាពនិងប្រតិបត្តិការនានារបស់រដ្ឋតាមប្រព័ន្ធអេឡិចត្រូនិក។

១២-វិធីគិតអាករជំនួស សំដៅដល់ វិធីសាស្ត្រដែលបុគ្គលទទួលការផ្គត់ផ្គង់ទំនិញឬសេវា ត្រូវគិតអាករលើតម្លៃបន្ថែមជំនួសបុគ្គលដែលធ្វើការផ្គត់ផ្គង់ជាប់អាករ។

១៣-អាករ ក្នុងជំពូកទាំងឡាយនៃអនុក្រឹត្យនេះ សំដៅដល់ អាករលើតម្លៃបន្ថែម។

## ជំពូកទី២
## បុគ្គលជាប់អាករ និងអាករលើធាតុចូល

### ផ្នែកទី១
### ការចុះបញ្ជីជាបុគ្គលជាប់អាករ

**មាត្រា៤ ._**

១-អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលបានធ្វើការផ្គត់ផ្គង់ជាប់អាករដូចមានចែងក្នុងមាត្រា៥៩ នៃច្បាប់ស្តីពីសារពើពន្ធ គឺជាបុគ្គលជាប់អាករ។ បុគ្គលជាប់អាករ ត្រូវដាក់ពាក្យស្នើសុំទៅអគ្គនាយកដ្ឋានពន្ធដារ ដើម្បីធ្វើការចុះបញ្ជីអាករលើតម្លៃបន្ថែមឱ្យបានស្រេចបាច់ក្នុងរយៈពេល ១៥ថ្ងៃ ក្រោយថ្ងៃដែលបុគ្គលនោះក្លាយជាបុគ្គលជាប់អាករដូចមានចែងក្នុងមាត្រា៧៧ នៃច្បាប់ស្តីពីសារពើពន្ធ។

២-រាល់អ្នកជាប់ពន្ធអនិវាសនជនដែលមិនមានគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវមានកាតព្វកិច្ចចុះបញ្ជីអាករលើតម្លៃបន្ថែមសាមញ្ញ ដោយផ្អែកតាមចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៥ ._**

១- បុគ្គលជាប់អាករដែលបានចុះបញ្ជីអាករលើតម្លៃបន្ថែម នឹងត្រូវទទួលបាននូវវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែមដែលមានលេខអត្តសញ្ញាណកម្មសារពើពន្ធ និងកាលបរិច្ឆេទមានប្រសិទ្ធភាពនៃការចុះបញ្ជី។ កាលបរិច្ឆេទមានប្រសិទ្ធភាពនៃការចុះបញ្ជីចាប់ផ្តើមពីដើមខែ បន្ទាប់ពីខែដែលកាតព្វកិច្ចដាក់ពាក្យស្នើសុំចុះបញ្ជីបានកើតមានឡើង។

២- បុគ្គលជាប់អាករដែលបានចុះបញ្ជីត្រូវដាក់តាំងឬព្យួរវិញ្ញាបនបត្រចុះបញ្ជីដែលបានចេញឱ្យនៅទីកន្លែងអាជីវកម្មជាសំខាន់របស់ខ្លួន។

### ផ្នែកទី២
### ការលុបចោលការចុះបញ្ជី

**មាត្រា៦ ._**

បុគ្គលជាប់អាករ ត្រូវស្នើសុំជាលាយលក្ខណ៍អក្សរទៅអគ្គនាយកដ្ឋានពន្ធដារឱ្យលុបចោលការចុះបញ្ជីរបស់ខ្លួន ប្រសិនបើបុគ្គលនោះឈប់ធ្វើការផ្គត់ផ្គង់ទំនិញឬសេវាដោយមានតម្លៃ ដែលជាចំណែកមួយនៃសកម្មភាពអាជីវកម្មរបស់ខ្លួន។

**មាត្រា៧ ._**

អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ មានសិទ្ធិលុបចោលការចុះបញ្ជីរបស់៖

១- បុគ្គលដែលបានស្នើសុំលុបតាមមាត្រា៦ នៃអនុក្រឹត្យនេះ។

២-បុគ្គលដែលមិនបានស្នើសុំលុបការចុះបញ្ជី ដោយអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារយល់ឃើញថា បុគ្គលនោះគ្មានការតម្រូវឬគ្មានសិទ្ធិចុះបញ្ជីតាមមាត្រា៤ នៃអនុក្រឹត្យនេះ។

៣-បុគ្គលដែលមិនបានដាក់ពាក្យស្នើសុំលុបចោលការចុះបញ្ជី ក៏ប៉ុន្តែមិនបានប្រកាសអំពីការផ្គត់ផ្គង់ជាប់អាករក្នុងរយៈពេល៣ខែប្រតិទិនជាប់គ្នា។

**មាត្រា៨ .-**

អគ្គនាយកដ្ឋានពន្ធដារ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់បុគ្គលជាប់អាករពីការសម្រេចយល់ព្រម ឬមិនយល់ព្រមលុបចោលការចុះបញ្ជីតាមមាត្រា៦ នៃអនុក្រឹត្យនេះ ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយពេលទទួលពាក្យស្នើសុំលុបចោលការចុះបញ្ជី ឬក្នុងរយៈពេល ៣០ថ្ងៃ ក្រោយការសម្រេចលុបចោលការចុះបញ្ជីតាមកថាខណ្ឌទី២ និងកថាខណ្ឌទី៣ នៃមាត្រា៧ នៃអនុក្រឹត្យនេះ។

**មាត្រា៩ .-**

នៅពេលដែលបុគ្គលជាប់អាករ ត្រូវបានលុបចេញពីបញ្ជីតាមជំពូកនេះ បុគ្គលជាប់អាករនោះត្រូវបានចាត់ទុកថាបានធ្វើការផ្គត់ផ្គង់ជាប់អាករនូវទំនិញទាំងអស់ដែលមាននៅក្នុងដៃ រួមទាំងទ្រព្យសកម្មផង ហើយត្រូវទទួលខុសត្រូវក្នុងការបង់អាករលើធាតុចេញលើរាល់ទំនិញទាំងអស់នោះដែលបានទទួលឥណទានអាករលើធាតុចូលរួចមកហើយ។ អាករលើធាតុចេញដែលត្រូវបង់ ត្រូវផ្អែកតាមតម្លៃទីផ្សារនៃទំនិញនៅពេលលុបចោលការចុះបញ្ជីនោះ។

**មាត្រា១០ .-**

ការលុបចោលការចុះបញ្ជីរបស់បុគ្គល ពុំមានផលប៉ះពាល់ដល់កាតព្វកិច្ចបំណុល និងទណ្ឌកម្មរបស់បុគ្គលដូចមានចែងក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ រួមទាំងការតម្រូវឱ្យដាក់លិខិតប្រកាសតាមមាត្រា៧១ នៃច្បាប់ស្តីពីសារពើពន្ធ ដែលបុគ្គលបានធ្វើឬមិនបានធ្វើនៅពេលដែលខ្លួនជាបុគ្គលជាប់អាករ។

## ផ្នែកទី៣
## ឥណទានអាករលើធាតុចូល

**មាត្រា១១ .-**

ឥណទានអាករលើធាតុចូលនៅពេលបុគ្គលត្រូវបានចុះបញ្ជីជាបុគ្គលជាប់អាករ ត្រូវបានកំណត់ដូចខាងក្រោម៖

១- បុគ្គលជាប់អាករត្រូវបានអនុញ្ញាតនូវឥណទានអាករលើធាតុចូល ដែលបានបង់ឬត្រូវបង់ចំពោះការផ្គត់ផ្គង់ជាប់អាករទាំងអស់នូវទំនិញ រួមទាំងទ្រព្យសកម្មជាមូលធន ដែលបុគ្គលបានទទួលមុនពេលចុះបញ្ជី។

២- លក្ខខណ្ឌនៃការអនុញ្ញាតឱ្យជាឥណទាន ត្រូវបានកំណត់ដូចខាងក្រោម៖

ក- ទំនិញត្រូវបានទិញសម្រាប់ការលក់ជាប់អាករឬសម្រាប់ប្រើប្រាស់ដើម្បីធ្វើការផ្គត់ផ្គង់ជាប់អាកររបស់បុគ្គលជាប់អាករ។

ខ- ទំនិញដែលមានចុះក្នុងបញ្ជីសារពើភណ្ឌ ត្រូវនៅក្នុងដៃនាកាលបរិច្ឆេទមានប្រសិទ្ធភាពនៃការចុះបញ្ជី។

គ- ការផ្គត់ផ្គង់ ឬការនាំចូលទាំងនោះត្រូវបានធ្វើឡើងមិនលើសពី ៦០ថ្ងៃ មុនកាលបរិច្ឆេទមានប្រសិទ្ធភាពនៃការចុះបញ្ជី។

ឃ- ពាក្យស្នើសុំឥណទាន ត្រូវបានធ្វើឡើងតាមទម្រង់ដែលអគ្គនាយកដ្ឋានពន្ធដារបានកំណត់។

ង- ត្រូវមានឯកសារភស្តុតាងត្រឹមត្រូវច្បាស់លាស់ជូនអគ្គនាយកដ្ឋានពន្ធដារបញ្ជាក់ថា បុគ្គលបានបង់អាករពិតមែនដែលអាចអនុញ្ញាតជាឥណទាន។

**មាត្រា១២ .-**

១- នៅពេលបុគ្គលជាប់អាករគណនាប្រាក់អាករដែលត្រូវបង់ក្នុងខែ បុគ្គលជាប់អាករនោះត្រូវបានអនុញ្ញាតឱ្យជាឥណទានសម្រាប់តែអាករដែលបានបង់លើ៖

ក- រាល់ការផ្គត់ផ្គង់ជាប់អាករដែលបុគ្គលជាប់អាករបានទទួលក្នុងខែ ឬយ៉ាងយឺតបំផុត ៦០ថ្ងៃ ក្រោយពេលទទួលការផ្គត់ផ្គង់។

ខ- រាល់ការនាំចូលទំនិញដោយបុគ្គលជាប់អាករក្នុងខែ ឬយ៉ាងយឺតបំផុត ៦០ថ្ងៃ ក្រោយពេលនាំចូល។

២- ឥណទានអាករលើធាតុចូលត្រូវកើតមានឡើង នៅពេលដូចខាងក្រោម៖

ក- នៅពេលដែលទំនិញឬសេវាត្រូវបានផ្គត់ផ្គង់ឱ្យបុគ្គលជាប់អាករឬនាំចូលដោយបុគ្គលជាប់អាករ។

ខ- នៅពេលបុគ្គលជាប់អាករត្រូវបានចុះបញ្ជី ក្នុងករណីឥណទានអាករដូចមានចែងក្នុងមាត្រា១១ នៃអនុក្រឹត្យនេះ។

ឥណទានអាករត្រូវបានអនុញ្ញាតផ្តល់ឱ្យតែចំពោះការផ្គត់ផ្គង់ជាប់អាករឬការនាំចូលសម្រាប់ប្រើប្រាស់ដើម្បីធ្វើការផ្គត់ផ្គង់ជាប់អាករតែប៉ុណ្ណោះ។

**មាត្រា១៣ .-**

បុគ្គលជាប់អាករមិនត្រូវបានអនុញ្ញាតឱ្យជាឥណទានអាករលើធាតុចូលទេ ចំពោះប្រាក់អាករដែលបានបង់លើ៖

១- ចំណាយទទួលភ្ញៀវ ការកម្សាន្ត ឬការសម្រាកលំហែ លើកលែងតែបុគ្គលជាប់អាករប្រកបអាជីវកម្មជាអ្នកផ្គត់ផ្គង់ការទទួលភ្ញៀវ ការកម្សាន្ត ឬការសម្រាកលំហែ។

២- ការទិញឬការនាំចូលរថយន្ត លើកលែងតែបុគ្គលជាប់អាករប្រកបអាជីវកម្មជាអ្នកលក់ឬជួលរថយន្ត។

៣- ការទិញឬការនាំចូលផលិតផលតេលសិលាមួយចំនួន លើកលែងតែបុគ្គលជាប់អាករប្រកបអាជីវកម្មជាអ្នកផ្គត់ផ្គង់ផលិតផលតេលសិលាទាំងនោះ។

៤- សម្រាប់គោលដៅនៃមាត្រានេះ៖

ក- ការទទួលភ្ញៀវ សំដៅដល់ ការផ្គត់ផ្គង់ម្ហូបអាហារ ភេសជ្ជៈ ថ្នាំជក់ កន្លែងស្នាក់អាស្រ័យ ឬបដិសណ្ឋារកិច្ចណាមួយ។

ខ- រថយន្ត សំដៅដល់ រថយន្តសម្រាប់តែដឹកមនុស្សដែលមានកន្លែងអង្គុយមិនលើសពី ១០កៅអី។

គ- ផលិតផលតេលសិលា សំដៅដល់ ប្រេងសាំងធម្មតា ប្រេងសាំងស៊ុបពែរ ប្រេងម៉ាស៊ូត និងប្រេងរំអិល។

**មាត្រា១៤ .-**

ក្នុងករណីទំនិញឬសេវាទិញចូល ត្រូវបានប្រើប្រាស់មួយចំណែកជាការផ្គត់ផ្គង់ជាប់អាករនិងមួយចំណែកទៀតជាការផ្គត់ផ្គង់មិនជាប់អាករ ឥណទានអាករលើធាតុចូលត្រូវបានអនុញ្ញាតឱ្យតែចំពោះចំណែកដែលបានប្រើប្រាស់ជាការផ្គត់ផ្គង់ជាប់អាករប៉ុណ្ណោះ។ ក្នុងករណីនេះ បុគ្គលជាប់អាករត្រូវធ្វើការកត់ត្រា និងបែងចែកឱ្យបានច្បាស់លាស់នូវទឹកប្រាក់អាករលើធាតុចូលដែលបានប្រើប្រាស់សម្រាប់ការផ្គត់ផ្គង់ជាប់អាករ និងអាករលើធាតុចូលដែលបានប្រើប្រាស់សម្រាប់ការផ្គត់ផ្គង់មិនជាប់អាករ។ អាករលើធាតុចូលដែលបានប្រើប្រាស់សម្រាប់ការផ្គត់ផ្គង់មិនជាប់អាករមិនត្រូវបានអនុញ្ញាតជាឥណទានអាករលើធាតុចូលទេ។

**មាត្រា១៥ .-**

១- ក្នុងករណីដែលអាករលើធាតុចូលនៅក្នុងរយៈពេលជាប់អាករមិនអាចបែងចែកបានរវាងការផ្គត់ផ្គង់ជាប់អាករ និងការផ្គត់ផ្គង់មិនជាប់អាករ ចំនួនឥណទានអាករលើធាតុចូលដែលអាចផ្តល់ឱ្យត្រូវគណនាតាមរូបមន្ត $ក \times \frac{ខ}{គ}$ ។

ក = ទឹកប្រាក់សរុបនៃអាករលើធាតុចូលក្នុងរយៈពេលជាប់អាករ។

ខ = តម្លៃសរុបមិនទាន់គិតអាករនៃការផ្គត់ផ្គង់ជាប់អាករដែលធ្វើឡើងដោយបុគ្គលជាប់អាករក្នុងរយៈពេលជាប់អាករ។

គ = តម្លៃសរុបមិនទាន់គិតអាករនៃការផ្គត់ផ្គង់ជាប់អាករនិងការផ្គត់ផ្គង់មិនជាប់អាករដែលធ្វើឡើងដោយបុគ្គលជាប់អាករក្នុងរយៈពេលជាប់អាករ លើកលែងតែតម្លៃនៃការផ្គត់ផ្គង់មិនជាប់អាករនៃការផ្ទេរអាជីវកម្ម។

២- ក្នុងករណីដែលប្រភាគ $\frac{ខ}{គ}$ មានតម្លៃតិចជាង ០,០៥ បុគ្គលជាប់អាករមិនត្រូវបានអនុញ្ញាតនូវឥណទានអាករលើធាតុចូលនៅក្នុងរយៈពេលជាប់អាករទេ។

៣- ក្នុងករណីដែលប្រភាគ $\frac{ខ}{គ}$ មានតម្លៃច្រើនជាង ០,៩៥ បុគ្គលជាប់អាករត្រូវបានអនុញ្ញាតនូវឥណទានអាករលើធាតុចូលទាំងអស់នៅក្នុងរយៈពេលជាប់អាករ។

៤- ក្នុងករណីដែលប្រភាគ $\frac{ខ}{គ}$ មានតម្លៃចាប់ពី ០,០៥ ដល់ ០,៩៥ បុគ្គលជាប់អាករត្រូវបានអនុញ្ញាតនូវឥណទានអាករលើធាតុចូលតាមសមាមាត្រនៃរូបមន្តដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

តម្លៃនៃប្រភាគ $\frac{ខ}{គ}$ ត្រូវកំណត់យកត្រឹមពីរខ្ទង់ក្រោយកណ្ដុកសញ្ញាដោយមិនមានការតម្រឹមលើក្រោមទេ។

**មាត្រា១៦ .-**

ក្នុងករណីដែលបុគ្គលជាប់អាករធ្វើការផ្គត់ផ្គង់ជាប់អាករផងនិងការផ្គត់ផ្គង់មិនជាប់អាករផង មានផលវិបាកដោយសារការអនុវត្តតាមកថាខណ្ឌទី១ នៃមាត្រា១៥ នៃអនុក្រឹត្យនេះ បុគ្គលជាប់អាករអាចអនុវត្តតាមរបៀបមួយផ្សេងទៀតដូចខាងក្រោមនេះ ដើម្បីគណនាអាករលើធាតុចូលដែលអាចកាត់កងបាន៖

១- បែងចែកអាករលើធាតុចូលនៃការផ្គត់ផ្គង់ជាប់អាករនិងអាករលើធាតុចូលនៃការផ្គត់ផ្គង់មិនជាប់អាករក្នុងករណីដែលអាចធ្វើទៅបាន។ ក្នុងករណីនេះ បុគ្គលជាប់អាករអាចស្នើសុំឥណទានអាករលើធាតុចូលទាំងអស់ដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់ជាប់អាករ តែមិនអាចស្នើសុំឥណទានអាករលើធាតុចូលដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់មិនជាប់អាករទេ។

២- ចំពោះអាករលើធាតុចូលនៅសល់ដែលមិនអាចបែងចែកបាន ឥណទានអាករត្រូវគណនាតាមកថាខណ្ឌទី១ នៃមាត្រា១៥ នៃអនុក្រឹត្យនេះ។

**មាត្រា១៧ .-**

នៅក្នុងខែដំបូងនៃឆ្នាំប្រតិទិនបន្ទាប់ បុគ្គលជាប់អាករដែលបានគណនាអាករលើធាតុចូលតាមកថាខណ្ឌទី១ នៃមាត្រា១៥ និងកថាខណ្ឌទី២ នៃមាត្រា១៦ នៃអនុក្រឹត្យនេះ ត្រូវធ្វើការគណនាឥណទានអាករដែលអាចកាត់កងបាន សម្រាប់ឆ្នាំប្រតិទិនកន្លងមក តាមរូបមន្តក្នុងកថាខណ្ឌទី១ នៃមាត្រា១៥ នៃអនុក្រឹត្យនេះ ដោយផ្អែកលើចំនួនទឹកប្រាក់សរុបប្រចាំឆ្នាំនៃ៖

១- អាករលើធាតុចូលដែលមិនអាចបែងចែកបាន។

២- ការផ្គត់ផ្គង់ជាប់អាករមិនទាន់គិតអាករ។

៣- ការផ្គត់ផ្គង់ជាប់អាករមិនទាន់គិតអាករនិងការផ្គត់ផ្គង់មិនជាប់អាករ លើកលែងតែការផ្គត់ផ្គង់មិនជាប់អាករនៃការផ្ទេរអាជីវកម្ម។

**មាត្រា១៨ .-**

១- ក្នុងករណីដែលឥណទានអាករប្រចាំឆ្នាំប្រតិទិនមានចំនួន៖

ក- ច្រើនជាងឥណទានអាករក្នុងលិខិតប្រកាស សមតុល្យត្រូវចាត់ទុកជាឥណទានអាករសម្រាប់ខែដំបូងនៃឆ្នាំប្រតិទិនបន្ទាប់។

ខ- តិចជាងឥណទានអាករក្នុងលិខិតប្រកាស សមតុល្យត្រូវចាត់ទុកជាឥណពន្ធអាករដែលត្រូវបង់តាមរយៈលិខិតប្រកាសអាករសម្រាប់ខែដំបូងនៃឆ្នាំប្រតិទិនបន្ទាប់។

២- សម្រាប់គោលដៅនៃមាត្រានេះ៖

ក- ឥណទានអាករប្រចាំឆ្នាំប្រតិទិន សំដៅដល់ អាករលើធាតុចូលសរុបដែលអាចកាត់កងបានសម្រាប់ឆ្នាំប្រតិទិន ដោយផ្អែកលើការគណនាសរុបប្រចាំឆ្នាំ។

ខ- ឥណទានអាករក្នុងលិខិតប្រកាស សំដៅដល់ អាករលើធាតុចូលសរុបដែលបានស្នើសុំជាឥណទានក្នុងខែនីមួយៗនៃឆ្នាំប្រតិទិន។

គ- ឥណពន្ធអាករ សំដៅដល់ ឥណទានអាករប្រចាំឆ្នាំប្រតិទិនតិចជាងឥណទានអាករក្នុងលិខិតប្រកាស។

ឃ-សមតុល្យ សំដៅដល់ ចំនួនលម្អៀងនៃឥណទានអាករប្រចាំឆ្នាំប្រតិទិន និងឥណទានអាករក្នុងលិខិតប្រកាស។

**មាត្រា១៩ .-**

ដើម្បីស្នើសុំឥណទានអាករលើធាតុចូលដែលអាចកាត់កងបានតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ បុគ្គលជាប់អាករត្រូវមាន៖

១- ច្បាប់ដើមនៃវិក្កយបត្រអាករដែលចេញដោយបុគ្គលជាប់អាករជាអ្នកផ្គត់ផ្គង់។

២- ប្រតិវេទន៍គយនាំចូលនិងបង្កាន់ដៃបង់ប្រាក់ពន្ធជាភស្តុតាងនៃទឹកប្រាក់អាករដែលបានបង់លើការនាំចូលទំនិញ។

**មាត្រា២០ .-**

ការបង្វិលសងឥណទានអាករលើធាតុចូលលើស ត្រូវបានកំណត់ដូចខាងក្រោម៖

១- បុគ្គលជាប់អាករដែលធ្វើការនាំចេញដូចមានចែងក្នុងមាត្រា៧៣ និងមាត្រា៧៤ នៃច្បាប់ស្តីពីសារពើពន្ធ បុគ្គលនោះអាចស្នើសុំបង្វិលសងឥណទានអាករលើធាតុចូលលើសជារៀងរាល់ខែ។ រីឯបុគ្គលជាប់អាករដទៃទៀតរួមទាំងគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលមានឥណទានអាករលើធាតុចូលលើសក្នុងរយៈពេល ៣ខែជាប់បន្ត ឬច្រើនជាង បុគ្គលនោះអាចស្នើសុំទៅអគ្គនាយកដ្ឋានពន្ធដារឱ្យបង្វិលសងនូវឥណទានអាករលើធាតុចូលលើសនោះ នៅដំណាច់ខែទី៣ឬនៅក្នុងខែណាមួយជាបន្តមកទៀត។

២- ចំពោះបុគ្គលជាប់អាករដែលបានស្នើសុំបង្វិលសងឥណទានអាករលើធាតុចូលលើសរួចហើយ ក៏ប៉ុន្តែមិនបានប្រកាសនូវការផ្គត់ផ្គង់ជាប់អាករ អគ្គនាយកដ្ឋានពន្ធដារមិនត្រូវធ្វើការបង្វិលសងឡើយ។

៣- ការបង្វិលសងឥណទានអាករលើធាតុចូលលើស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៤
## វិក្កយបត្រអាករ

**មាត្រា២១ .-**

ការប្រើប្រាស់វិក្កយបត្រអាករ ត្រូវអនុវត្តដូចខាងក្រោម៖

១- បុគ្គលជាប់អាករដែលធ្វើការផ្គត់ផ្គង់ទំនិញឬសេវា ត្រូវចេញវិក្កយបត្រអាករឱ្យទៅអ្នកទិញដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស និងត្រូវចេញវិក្កយបត្រធម្មតាទៅឱ្យអ្នកទិញដែលមិនស្ថិតនៅក្រោមរបបស្វ័យប្រកាស។

២- បុគ្គលដែលទទួលការផ្គត់ផ្គង់ត្រូវទាមទារឱ្យបុគ្គលជាប់អាករដែលធ្វើការផ្គត់ផ្គង់ទំនិញឬសេវា ផ្តល់វិក្កយបត្រនៃការផ្គត់ផ្គង់នោះ។

៣- បុគ្គលជាប់អាករដែលធ្វើការផ្គត់ផ្គង់ទំនិញឬសេវា ត្រូវរក្សាច្បាប់ដើមនៃវិក្កយបត្រអាករឬវិក្កយបត្រធម្មតា និងឯកសារផ្សេងទៀតដែលបានចេញឱ្យអតិថិជន។

៤- វិក្កយបត្រអាករឬវិក្កយបត្រធម្មតា ត្រូវមាននិទ្ទេសគ្រប់គ្រាន់តាមវិធានវិក្កយបត្រដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៣
## ការផ្គត់ផ្គង់មិនជាប់អាករចំពោះបេសកកម្មទូតនិងអង្គការអន្តរជាតិ

**មាត្រា២២ .-**

ការផ្គត់ផ្គង់មិនជាប់អាករចំពោះបេសកកម្មទូតនិងកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលដទៃទៀត ត្រូវបានកំណត់ដូចខាងក្រោម៖

១- ការនាំចូលឬការទិញក្នុងស្រុកនូវទំនិញឬសេវាដោយបេសកកម្មទូតនិងកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលដទៃទៀត សម្រាប់យកមកប្រើនៅក្នុងការបំពេញមុខងារជាផ្លូវការរបស់ខ្លួន ត្រូវកំណត់ថាជាការផ្គត់ផ្គង់មិនជាប់អាករ។ ការផ្គត់ផ្គង់មិនជាប់អាករត្រូវបានផ្តល់ឱ្យតែក្នុងករណីមានការបញ្ជាក់ពីប្រធានបេសកកម្មជូនរដ្ឋបាលសារពើពន្ធថា ការនាំចូលឬការទិញក្នុងស្រុកនូវទំនិញឬសេវាទាំងនោះសម្រាប់គោលដៅនៃការប្រើប្រាស់ខាងលើតែប៉ុណ្ណោះ។

២- ការនាំចូលឬការទិញក្នុងស្រុកនូវទំនិញឬសេវាសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនរបស់បុគ្គលិកផ្លូវការនៃបេសកកម្មទូតនិងកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលដទៃទៀតដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ ត្រូវកំណត់ថាជាការផ្គត់ផ្គង់មិនជាប់អាករចំពោះតែមុខទំនិញឬសេវាទាំងឡាយណាដែលមានចុះនៅក្នុងបញ្ជីរាយមុខទំនិញឬសេវា ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៣- ការផ្គត់ផ្គង់មិនជាប់អាករនៅក្នុងមាត្រានេះ ត្រូវឈរលើគោលការណ៍បដិការរវាងរដ្ឋាភិបាលពាក់ព័ន្ធ។

## ជំពូកទី៤
## ទីកន្លែង វិធាន និងនីតិវិធីសម្រាប់ការផ្គត់ផ្គង់ជាប់អាករ

### មាត្រា២៣ .-

ទីកន្លែងផ្គត់ផ្គង់ ត្រូវបានកំណត់ដូចខាងក្រោម៖

១- ការផ្គត់ផ្គង់ទំនិញត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើទំនិញនោះត្រូវបានប្រគល់ឱ្យ ទោះបីមានលក្ខណៈជាការផ្ទេរសិទ្ធិប្រើប្រាស់ឬសិទ្ធិចាត់ចែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ចំពោះករណីដែលការផ្គត់ផ្គង់ត្រូវមានការដឹកជញ្ជូន ការផ្គត់ផ្គង់ត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើទំនិញស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជានៅពេលដែលការដឹកជញ្ជូនត្រូវបានចាប់ផ្ដើម។

២- ការផ្គត់ផ្គង់សេវាត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើសេវានោះបានបំពេញនៅក្នុងព្រះរាជាណាចក្រកម្ពុជា វៀរលែងតែ៖

- ក- ការផ្គត់ផ្គង់សេវាជាប់ទាក់ទិននឹងអចលនទ្រព្យត្រូវកំណត់ថា សេវានោះបានធ្វើឡើងនៅទីកន្លែងដែលអចលនទ្រព្យនោះស្ថិតនៅ។
- ខ- ការផ្គត់ផ្គង់សេវាជាប់ទាក់ទិននឹងការដឹកជញ្ជូនត្រូវកំណត់ថា សេវានោះបានធ្វើឡើងនៅទីកន្លែងនៃការដឹកជញ្ជូននោះ។

៣- ចំពោះសេវាដែលបានផ្គត់ផ្គង់នៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយបុគ្គលអនិវាសនជន បុគ្គលជាប់អាករដែលជាអ្នកទទួលការផ្គត់ផ្គង់ត្រូវគិតអាករជំនួសអ្នកផ្គត់ផ្គង់និងបង់ប្រាក់អាករជូនរដ្ឋបាលសារពើពន្ធ ប្រសិនបើអ្នកផ្គត់ផ្គង់នោះពុំមានគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៤- ទំនិញត្រូវចាត់ទុកថា បាននាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើទំនិញនោះត្រូវបាននាំចូលមកក្នុងដែនគយនៃព្រះរាជាណាចក្រកម្ពុជា។

### មាត្រា២៤ .-

ក្នុងករណីដែលបុគ្គលជាប់អាករធ្វើការផ្គត់ផ្គង់លាយឡំគ្នារវាងទំនិញនិងសេវា ការផ្គត់ផ្គង់ទាំងនោះត្រូវបានកំណត់ដូចខាងក្រោម៖

១- ការផ្គត់ផ្គង់នូវសេវាបន្ទាប់បន្សំដែលរួមជាមួយនឹងការផ្គត់ផ្គង់ទំនិញ គឺជាចំណែកមួយនៃការផ្គត់ផ្គង់ទំនិញ។

២- ការផ្គត់ផ្គង់នូវទំនិញបន្ទាប់បន្សំដែលរួមជាមួយនឹងការផ្គត់ផ្គង់សេវា គឺជាចំណែកមួយនៃការផ្គត់ផ្គង់សេវា។

៣- ការផ្គត់ផ្គង់នូវសេវាបន្ទាប់បន្សំដែលរួមជាមួយនឹងការនាំចូល គឺជាចំណែកមួយនៃការនាំចូល។

### មាត្រា២៥ .-

ពេលផ្គត់ផ្គង់ ត្រូវបានកំណត់ដូចខាងក្រោមនេះ ដើម្បីគណនាប្រាក់អាករសម្រាប់រយៈពេលជាប់អាករនីមួយៗដែលបុគ្គលជាប់អាករត្រូវប្រកាសបង់ជូនអគ្គនាយកដ្ឋានពន្ធដារ៖

១- ពេលផ្គត់ផ្គង់ទំនិញឬសេវា ត្រូវបានកំណត់ដូចខាងក្រោម៖

- ក- ពេលផ្គត់ផ្គង់ទំនិញឬសេវា គឺជាពេលដែលអ្នកផ្គត់ផ្គង់ត្រូវចេញវិក្កយបត្រឬជាពេលដែលអ្នកផ្គត់ផ្គង់បានចេញវិក្កយបត្រប្រសិនបើវិក្កយបត្រនោះត្រូវបានចេញមុនពេលដែលអ្នកផ្គត់ផ្គង់ត្រូវចេញវិក្កយបត្រ។ អ្នកផ្គត់ផ្គង់ត្រូវចេញវិក្កយបត្រយ៉ាងយឺតបំផុត ៧ថ្ងៃ ក្រោយការបញ្ជូនទំនិញឬការបំពេញសេវាឬក្រោយការទូទាត់ក្នុងករណីដែលការទូទាត់ត្រូវបានធ្វើឡើងមុនការបញ្ជូនទំនិញឬការបំពេញសេវា។

ខ- ក្នុងករណីដែលទំនិញត្រូវបានយកទៅប្រើប្រាស់ផ្ទាល់ខ្លួន ពេលផ្គត់ផ្គង់គឺជាពេលដែលទំនិញនោះត្រូវបានយកទៅប្រើប្រាស់ដំបូង។

គ- ក្នុងករណីទំនិញឬសេវាត្រូវបានផ្គត់ផ្គង់ក្នុងលក្ខណៈជាអំណោយ ពេលផ្គត់ផ្គង់គឺជាពេលដែលទំនិញត្រូវបានប្រគល់ឱ្យទោះមានលក្ខណៈជាការផ្ទេរសិទ្ធិប្រើប្រាស់ឬសិទ្ធិចាត់ចែងក្តី ឬពេលដែលសេវាផ្គត់ផ្គង់ឱ្យត្រូវបានបំពេញរួចរាល់។

២-ពេលផ្គត់ផ្គង់ទំនិញក្រោមកិច្ចសន្យាជួលដោយមានលក្ខខណ្ឌទិញផ្តាច់ឬកតិសន្យាហិរញ្ញវត្ថុ គឺជាពេលដែលទំនិញត្រូវបានប្រគល់ឱ្យទោះមានលក្ខណៈជាការផ្ទេរសិទ្ធិប្រើប្រាស់ឬសិទ្ធិចាត់ចែងក្តី។

៣-ទំនិញឬសេវា ត្រូវចាត់ទុកថាបានផ្គត់ផ្គង់រួចរាល់ចំពោះចំណែកដែលបានផ្គត់ផ្គង់រួចរាល់ក្នុងរយៈពេលនៃកិច្ចសន្យាឬរយៈពេលដែលច្បាប់បានកំណត់ ហើយពេលផ្គត់ផ្គង់នៃចំណែកដែលបានផ្គត់ផ្គង់រួចរាល់នីមួយៗគឺជាកាលបរិច្ឆេទមុនគេក្នុងចំណោមកាលបរិច្ឆេទដែលការទូទាត់ត្រូវដល់កំណត់និងកាលបរិច្ឆេទដែលបានទទួលការទូទាត់។ ពេលផ្គត់ផ្គង់ដូចមានចែងក្នុងកថាខណ្ឌនេះ អនុវត្តចំពោះទំនិញត្រូវបានផ្គត់ផ្គង់ក្រោមកិច្ចសន្យាជួលឬទំនិញឬសេវាត្រូវបានផ្គត់ផ្គង់ក្រោមកិច្ចសន្យាឬច្បាប់ដែលចែងអំពីការទូទាត់ច្រើនលើក ឬសេវាត្រូវបានផ្គត់ផ្គង់ជាប់បន្ត។

៤- ចំពោះការនាំចូលទំនិញ ពេលផ្គត់ផ្គង់គឺជាពេលដែលអ្នកនាំចូលដាក់លិខិតប្រកាសជូនរដ្ឋបាលគយស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## មាត្រា២៦ .-

តម្លៃជាប់អាករនៃការផ្គត់ផ្គង់ត្រូវបានកំណត់ដូចខាងក្រោម៖

១- តម្លៃជាប់អាករនៃការផ្គត់ផ្គង់ គឺជាថ្លៃទំនិញឬសេវាដែលបុគ្គលជាប់អាករគិតយកពីអតិថិជនដែលជាអ្នកទិញ។ តម្លៃជាប់អាកររួមមានថ្លៃទំនិញឬសេវា តម្លៃដឹកជញ្ជូន និងខ្ទង់ដទៃទៀតដែលត្រូវទូទាត់ឱ្យបុគ្គលជាប់អាករ រួមបញ្ចូលអាករនានាដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់នោះ លើកលែងតែអាករលើតម្លៃបន្ថែម។

២- ក្នុងករណីដែលការទូទាត់ចំពោះការផ្គត់ផ្គង់ជាប់អាករជាសំណងអ្វីមួយក្រៅពីប្រាក់កាស ដើម្បីជាផលប្រយោជន៍ផ្ទាល់ឬប្រយោលដល់អ្នកលក់ សំណងនោះត្រូវគិតបញ្ចូលក្នុងតម្លៃជាប់អាករតាមតម្លៃទីផ្សារ។

៣- តម្លៃជាប់អាកររបស់ទំនិញនាំចូល គឺជាតម្លៃគិតពន្ធគយ រួមបញ្ចូលទាំងពន្ធគយនិងអាករនានានៅពេលនាំចូល។

៤- ប្រសិនបើតម្លៃជាប់អាកររបស់ទំនិញឬសេវាដែលបានផ្គត់ផ្គង់មិនតំណាងឱ្យតម្លៃពិតទេនោះ អគ្គនាយកដ្ឋានពន្ធដារអាចកំណត់ចេញនូវតម្លៃមួយសម្រាប់ទំនិញឬសេវា ហើយតម្លៃនោះត្រូវចាត់ទុកជាតម្លៃត្រឹមត្រូវរហូតដល់ពេលមានភស្តុតាងបញ្ជាក់ផ្សេងដែលរដ្ឋបាលសារពើពន្ធបានយល់ព្រម។

៥- តម្លៃជាប់អាករនៃទំនិញដែលបានប្រើប្រាស់រួច ដែលបុគ្គលជាប់អាករបានទិញពីអ្នកប្រើប្រាស់ដើម្បីលក់ជាប្រចាំឬលក់ជំនួសមុខឱ្យអ្នកប្រើប្រាស់ គឺជាចំនួនលម្អៀងរវាងថ្លៃលក់និងថ្លៃទិញ ឬជាប្រាក់កម្រៃដែលបានមកពីការលក់ទំនិញនោះ។

## មាត្រា២៧ .-

អត្រាអាករលើតម្លៃបន្ថែម ត្រូវបានកំណត់ដូចខាងក្រោម៖

១- អាករលើតម្លៃបន្ថែម ត្រូវកំណត់តាមអត្រា ១០ (ដប់) ភាគរយ លើតម្លៃជាប់អាករនៃការផ្គត់ផ្គង់ជាប់អាករនីមួយៗនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២- អាករលើតម្លៃបន្ថែម ត្រូវកំណត់តាមអត្រា ០ (សូន្យ) ភាគរយ លើតម្លៃជាប់អាករនៃការផ្គត់ផ្គង់ជាប់អាករនីមួយៗចំពោះទំនិញនាំចេញពីព្រះរាជាណាចក្រកម្ពុជា ឬការផ្គត់ផ្គង់សេវាជាប់អាករដែលបានបំពេញនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៥
## ការកែតម្រូវទឹកប្រាក់អាករ

**មាត្រា២៨.-**

វិធាននិងនីតិវិធីនៃការកែតម្រូវទឹកប្រាក់អាករនៅក្រោយពេលផ្គត់ផ្គង់ឬពេលចេញវិក្កយបត្រ ត្រូវបានកំណត់ដូចខាងក្រោម៖

១- បុគ្គលជាប់អាករដែលបានចេញវិក្កយបត្រឬបានដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែរួចហើយ បុគ្គលនោះអាចធ្វើការកែតម្រូវទឹកប្រាក់អាករឡើងវិញបាន ប្រសិនបើមានហេតុការណ៍ដូចខាងក្រោមនេះបានកើតឡើង៖

ក- ការផ្គត់ផ្គង់ត្រូវបានលុបចោល ឬ

ខ- ចរិតនៃការផ្គត់ផ្គង់ត្រូវបានប្រែប្រួលឬបានផ្លាស់ប្តូរជាមូលដ្ឋាន ឬ

គ- អត្ថប្រយោជន៍សម្រាប់ការផ្គត់ផ្គង់ដែលបានព្រមព្រៀងគ្នាពីពេលមុន ត្រូវបានកែប្រែដោយកិច្ចព្រមព្រៀងថ្មីជាមួយនឹងអ្នកទទួលការផ្គត់ផ្គង់ ដោយមូលហេតុនៃការបញ្ចុះថ្លៃឬដោយហេតុផលផ្សេងទៀត ឬ

ឃ-ទំនិញឬចំណែកណាមួយនៃទំនិញឬសំបកវេចខ្ចប់ ត្រូវបានបញ្ជូនត្រលប់មកអ្នកផ្គត់ផ្គង់វិញឬសេវាមិនត្រូវបានបំពេញរួចរាល់។

២-ក្នុងករណីមានការកែតម្រូវដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ បុគ្គលជាប់អាករត្រូវធ្វើការកែតម្រូវទឹកប្រាក់អាកររបស់ខ្លួនដូចខាងក្រោម៖

ក- ប្រសិនបើប្រាក់អាករលើធាតុចេញកែតម្រូវមានចំនួនលើសពីប្រាក់អាករលើធាតុចេញដែលបុគ្គលជាប់អាករបានកត់ត្រា ចំនួនលើសត្រូវបានចាត់ទុកជាប្រាក់អាករដែលបុគ្គលជាប់អាករបានប្រមូលនៅក្នុងខែដែលហេតុការណ៍ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះបានកើតឡើង។

ខ- ប្រសិនបើប្រាក់អាករលើធាតុចេញកែតម្រូវមានចំនួនតិចជាងប្រាក់អាករលើធាតុចេញដែលបុគ្គលជាប់អាករបានកត់ត្រា ចំនួនលម្អៀងត្រូវបានចាត់ទុកជាឥណទានអាករសម្រាប់ខែដែលហេតុការណ៍ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះបានកើតឡើង។

៣-ចំពោះការផ្គត់ផ្គង់ឱ្យបុគ្គលដែលមិនមែនជាបុគ្គលជាប់អាករ ប្រាក់អាករលើសដូចមានចែងក្នុងវាក្យខណ្ឌ ខ នៃកថាខណ្ឌទី២ នៃមាត្រានេះ មិនត្រូវបានអនុញ្ញាតជាឥណទានអាករទេ លើកលែងតែបុគ្គលជាប់អាករមានភស្តុតាងនៃការទូទាត់សងប្រាក់អាករលើសឱ្យអ្នកទទួលការផ្គត់ផ្គង់វិញ។

៤- ប្រសិនបើបុគ្គលជាប់អាករបានចេញវិក្កយបត្រអាកររួចហើយ មានការកែតម្រូវប្រាក់អាករដោយហេតុការណ៍ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ៖

ក- ចំនួនប្រាក់អាករដែលបានកែតម្រូវតិចជាងចំនួនប្រាក់អាករដែលបានកត់ត្រាក្នុងវិក្កយបត្រ បុគ្គលជាប់អាករដែលធ្វើការផ្គត់ផ្គង់ទំនិញឬសេវាត្រូវផ្តល់ឱ្យអ្នកទទួលការផ្គត់ផ្គង់នូវលិខិតឥណទានអាករដូចមានចែងក្នុងមាត្រា២១ នៃអនុក្រឹត្យនេះ។

ខ- ចំនួនប្រាក់អាករដែលបានកែតម្រូវច្រើនជាងចំនួនប្រាក់អាករដែលបានកត់ត្រាក្នុងវិក្កយបត្រ បុគ្គលជាប់អាករដែលធ្វើការផ្គត់ផ្គង់ទំនិញឬសេវា ត្រូវផ្តល់ឱ្យអ្នកទទួលការផ្គត់ផ្គង់នូវលិខិតឥណពន្ធអាករដូចមានចែងក្នុងមាត្រា២១ នៃអនុក្រឹត្យនេះ។

៥- បុគ្គលជាប់អាករជាអ្នកធ្វើការផ្គត់ផ្គង់ឬជាអ្នកទទួលការផ្គត់ផ្គង់ដែលបានចេញឬបានទទួលលិខិតឥណពន្ធឬលិខិតឥណទានអាករត្រូវកត់ត្រាចូលក្នុងទិនានុប្បវត្តិនូវទឹកប្រាក់ដែលមានបញ្ជាក់ក្នុងលិខិតឥណពន្ធឬលិខិតឥណទានអាករដូចគ្នាទៅនឹងការកត់ត្រាក្នុងទិនានុប្បវត្តិនូវទឹកប្រាក់នៃវិក្កយបត្រអាករដែរ។

# ជំពូកទី៦
# បញ្ជីគណនេយ្យ កំណត់ត្រា និងព័ត៌មាន

**មាត្រា២៩ .-**

១- បុគ្គលជាប់អាករត្រូវកាន់កត់ត្រាបញ្ជីគណនេយ្យនៃការផ្គត់ផ្គង់ទាំងអស់ដែលបានធ្វើ និងបានទទួលនៅក្នុងដំណើរការប្រកបអាជីវកម្មរួមទាំងការផ្គត់ផ្គង់ដែលជាប់អាករតាមអត្រា ០ (សូន្យ) ភាគរយ និងការផ្គត់ផ្គង់មិនជាប់អាករ។ សម្រាប់គោលដៅនៃអាករលើតម្លៃបន្ថែម បុគ្គលជាប់អាករត្រូវកាន់និងរក្សាបញ្ជីគណនេយ្យ កំណត់ត្រា និងព័ត៌មានដូចខាងក្រោម៖

ក- គណនីអាករលើតម្លៃបន្ថែមប្រចាំខែដែលបញ្ជាក់អំពីអាករលើធាតុចេញសរុប អាករលើធាតុចូលសរុប ប្រាក់អាករត្រូវបង់ ឬឥណទានអាករលើសត្រូវយោងទៅមុខឬដល់កំណត់ត្រូវបង្វិលសងវិញ។

ខ- កំណត់ត្រាទិញដែលលម្អិតអំពីការទិញដែលបានបង់អាករនិងការទិញទាំងអស់ដែលគ្មានបង់អាករ ច្បាប់ដើមនៃវិក្កយបត្រអាករសម្រាប់ការទិញក្នុងស្រុកដែលបានបង់អាករ ប្រតិវេទន៍គយនាំចូលបញ្ជាក់ដោយរដ្ឋបាលគយដែលបង្ហាញអំពីប្រាក់អាករបានបង់ និងវិក្កយបត្រទិញដែលគ្មានបង់អាករ។

គ- កំណត់ត្រាលក់ទាំងអស់ដែលរួមមានការលក់ជាប់អាករតាមអត្រា ១០ (ដប់) ភាគរយ អត្រា ០ (សូន្យ) ភាគរយ និងការលក់មិនជាប់អាករ។ ច្បាប់ដើមនៃវិក្កយបត្រទាក់ទិននឹងការលក់ជាប់អាករនិងលក់មិនជាប់អាករ។

ឃ-លិខិតឥណពន្ធនិងលិខិតឥណទានដែលបានចេញនិងបានទទួល។

ង- កំណត់ត្រាលើរាល់ការនាំចេញនូវទំនិញ ឬសេវាតាមអត្រា ០ (សូន្យ) ភាគរយ ព្រមទាំងប្រតិវេទន៍គយនាំចេញច្បាប់ដើមនៃវិក្កយបត្រដែលបានចេញឱ្យអ្នកទិញបរទេស ឯកសារដឹកជញ្ជូនសម្រាប់ការនាំចេញទំនិញ លិខិតបញ្ជាទិញឬកិច្ចសន្យាជាមួយអ្នកទិញបរទេស និងភស្តុតាងនៃការទូទាត់ប្រាក់តាមវិធីផ្ទេរប្រាក់តាមធនាគារដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬតាមលិខិតឥណទាន។ ចំពោះលិខិតឥណទានត្រូវមានចុះបញ្ជាក់ឱ្យបើកប្រាក់ទូទាត់ពីធនាគារ បានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលបានទទួលការយល់ព្រមណាមួយ។

ច- កំណត់ត្រាចលនាសាច់ប្រាក់របស់អ្នកលក់រាយដែលរួមមានបញ្ជីបេឡានិងបញ្ជីប្រាក់នៅធនាគារ បណ្ណចំណាយប្រាក់បេឡា និងកំណត់ត្រាគណនេយ្យផ្សេងទៀត រួមទាំងច្បាប់ដើមនៃបង្កាន់ដៃទទួលប្រាក់ ឬបញ្ជីលម្អិតអំពីចំនួនទឹកប្រាក់នៃការលក់ដូរប្រចាំថ្ងៃ។

ឆ- កំណត់ត្រាតាមទម្រង់ឌីជីថល ប្រសិនបើបុគ្គលជាប់អាករប្រើប្រាស់បញ្ជីគណនេយ្យដោយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

ជ- ព័ត៌មានលម្អិតស្តីពីការគណនាអាករលើធាតុចូល ក្នុងករណីដែលបុគ្គលជាប់អាករធ្វើការផ្គត់ផ្គង់ជាប់អាករផង និងការផ្គត់ផ្គង់មិនជាប់អាករផង។

ឈ-ឯកសារកំណត់ត្រានានា និងទម្រង់ស្នើសុំឥណទានអាករនៅពេលចុះបញ្ជីពន្ធដារ។

ញ-កំណត់ត្រាស្តុកដែលបង្ហាញអំពីការបញ្ចូលបញ្ចេញទំនិញ និងកំណត់ត្រាផលិតកម្ម។

ដ- កំណត់ត្រាបញ្ជាទិញ និងបណ្ណប្រគល់ទំនិញ។

ឋ- លិខិតឆ្លើយឆ្លងអាជីវកម្ម។

ឌ- សៀវភៅការងារ។

ឍ-របាយការណ៍គណនេយ្យប្រចាំឆ្នាំ រួមមានគណនីលទ្ធផល តារាងតុល្យការ និងតារាងព័ត៌មានបន្ថែម។

ណ-កំណត់ត្រាខាងធនាគារ រួមមានសម្រង់គណនី គល់សៀវភៅមូលប្បទានបត្រ និងបណ្ណបង់ប្រាក់ចូលធនាគារ។

២-កំណត់ត្រាទាំងអស់ ត្រូវធ្វើឡើងទៅតាមទម្រង់ដែលអគ្គនាយកដ្ឋានពន្ធដារបានកំណត់ឬបានទទួលស្គាល់ ហើយត្រូវថែរក្សាតាមលំដាប់ថ្ងៃខែនិងលេខរៀង និងត្រៀមបម្រុងសម្រាប់ការត្រួតពិនិត្យក្នុងរយៈពេល ១០ឆ្នាំ។

# ជំពូកទី៧
# ការផ្គត់ផ្គង់ទំនិញឬសេវា

## ផ្នែកទី១
## ការផ្គត់ផ្គង់ទំនិញឬសេវាដល់អ្នកប្រើប្រាស់

**មាត្រា៣០ .-**

១- បុគ្គលជាប់អាករដែលធ្វើការផ្គត់ផ្គង់ទំនិញឬសេវាដល់អ្នកជាប់ពន្ធដែលមិនមែនជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវកាន់បញ្ជីគណនេយ្យនិងកំណត់ត្រានានាដូចមានចែងក្នុងមាត្រា២៩ នៃអនុក្រឹត្យនេះ ហើយត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

ក- ក្នុងករណីដែលបានចេញវិក្កយបត្រធម្មតា ប្រសិនបើនៅលើវិក្កយបត្រមានបញ្ជាក់ចំនួនទឹកប្រាក់អាករដោយឡែកនោះ ប្រាក់អាករដល់កំណត់ក្នុងខែត្រូវគណនាចេញពីកំណត់ត្រាការលក់។

ខ- ប្រសិនបើនៅលើវិក្កយបត្រគ្មានបញ្ជាក់ចំនួនទឹកប្រាក់អាករដោយឡែកទេ ឬបុគ្គលជាប់អាករធ្វើការលក់រាយដោយមិនបានចេញវិក្កយបត្រ បុគ្គលជាប់អាករត្រូវកាន់កំណត់ត្រាការលក់សរុបប្រចាំថ្ងៃនៃការលក់ជាប់អាករនិងការលក់មិនជាប់អាករ។ ក្នុងការគណនាប្រាក់អាករ ត្រូវយកតម្លៃសរុបមានអាករនៃការលក់ទៅគុណនឹងប្រភាគអាករ។

២-ប្រភាគអាករសម្រាប់អត្រា ១០ (ដប់) ភាគរយ គឺ $\frac{១}{១១}$ ។

៣-ដើម្បីរកតម្លៃជាប់អាករត្រូវយកតម្លៃសរុបនៃការលក់ ដកទឹកប្រាក់អាករចេញ។

## ផ្នែកទី២
## ការផ្គត់ផ្គង់ទំនិញឬសេវាដោយសហគ្រាសជាភ្នាក់ងារ

**មាត្រា៣១ .-**

លក្ខខណ្ឌនៃការផ្គត់ផ្គង់ទំនិញឬសេវាដោយសហគ្រាសជាភ្នាក់ងារ ត្រូវបានកំណត់ដូចខាងក្រោម៖

១- ការផ្គត់ផ្គង់ទំនិញឬសេវាធ្វើឡើងដោយសហគ្រាសជាភ្នាក់ងារ ដើម្បីជាគុណប្រយោជន៍របស់សហគ្រាសមួយទៀតដែលជាសហគ្រាសដើម ត្រូវបានចាត់ទុកជាការផ្គត់ផ្គង់របស់សហគ្រាសដើមនោះ។

២- សហគ្រាសជាភ្នាក់ងារ ត្រូវគិតអាករលើប្រាក់កម្រៃដែលបានមកពីការធ្វើសេវាផ្គត់ផ្គង់ទំនិញឬសេវាឱ្យសហគ្រាសដើម ហើយប្រាក់អាករនេះគឺជាអាករលើធាតុចូលរបស់សហគ្រាសដើម។

៣-វិធាននិងនីតិវិធីសម្រាប់អនុវត្តមាត្រានេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

# ជំពូកទី៨
# ការប្រមូលអាករលើការនាំចូល

**មាត្រា៣២ .-**

ការប្រមូលអាករនៅពេលនាំចូល ត្រូវបានកំណត់ដូចខាងក្រោម៖

១- អាករដល់កំណត់នៅពេលនាំចូល និងត្រូវប្រមូលដោយរដ្ឋបាលគយ ហើយត្រូវបានចាត់ចែងតាមរបៀបដូចគ្នានឹងពន្ធគយ។

២- តម្លៃជាប់អាករនៃការនាំចូលទំនិញ គឺជាចំនួនសរុបនៃ៖

ក- តម្លៃទំនិញសម្រាប់គិតពន្ធគយស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីគយ។

ខ- ចំនួនទឹកប្រាក់នៃពន្ធគយ និងអាករនានានៅពេលនាំចូលក្រៅពីអាករលើតម្លៃបន្ថែម។

៣-រដ្ឋបាលគយ ត្រូវផ្តល់ឱ្យអ្នកនាំចូលនូវប្រេតិវេទន៍គយនាំចូលមួយច្បាប់ដែលក្នុងនោះត្រូវមាន៖

ក- លេខអត្តសញ្ញាណកម្មសារពើពន្ធ ប្រសិនបើអ្នកនាំចូលជាបុគ្គលជាប់អាករ។

ខ- សរសេរថា "គ្មាន" ក្នុងប្រអប់សម្រាប់លេខអត្តសញ្ញាណកម្មសារពើពន្ធ ប្រសិនបើអ្នកនាំចូលមិនមែនជាបុគ្គលជាប់អាករ។

គ- បង្កាន់ដៃបង់ពន្ធគយដែលមានបញ្ជាក់នូវចំនួនប្រាក់អាករដែលបានបង់។

ឃ-បញ្ជាក់អំពីសុពលភាពនៃការបង្វិលសងប្រាក់អាករ ប្រសិនបើអ្នកនាំចូលជាបុគ្គលជាប់អាករ។

ង- បញ្ជាក់អំពីអសុពលភាពនៃការបង្វិលសងប្រាក់អាករ ប្រសិនបើអ្នកនាំចូលមិនមែនជាបុគ្គលជាប់អាករ។

## ជំពូកទី៩
## ដែនអនុវត្តនៃអត្រា ០ (សូន្យ) ភាគរយ ចំពោះការនាំចេញនូវទំនិញឬសេវា

### មាត្រា៣៣ .-

ដែនអនុវត្តនៃអត្រា ០ (សូន្យ) ភាគរយ ចំពោះការនាំចេញនូវទំនិញឬសេវា ត្រូវបានកំណត់ដូចខាងក្រោម៖

១- អាករលើតម្លៃបន្ថែមត្រូវកំណត់តាមអត្រា ០ (សូន្យ) ភាគរយ លើតម្លៃជាប់អាករនៃការផ្គត់ផ្គង់ទំនិញនីមួយៗដែលបាននាំចេញពីព្រះរាជាណាចក្រកម្ពុជា ឬការផ្គត់ផ្គង់ជាប់អាករនៃសេវាដែលបានបំពេញនៅក្រៅព្រះរាជាណាចក្រកម្ពុជា។ ដែនអនុវត្តនៃបទប្បញ្ញត្តិនេះ ត្រូវរួមបញ្ចូល៖

ក- ការផ្គត់ផ្គង់ទំនិញទៅទីកន្លែងណាមួយនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

ខ- ការផ្គត់ផ្គង់សេវាសម្រាប់ប្រើប្រាស់នៅក្រៅព្រះរាជាណាចក្រកម្ពុជា។

គ- ការផ្គត់ផ្គង់សេវាដឹកជញ្ជូនអ្នកដំណើរនិងទំនិញជាអន្តរជាតិ។

ឃ-ការផ្គត់ផ្គង់សេវាដែលទាក់ទិននឹងការដឹកជញ្ជូនអ្នកដំណើរនិងទំនិញជាអន្តរជាតិ។

២- សម្រាប់គោលដៅនៃវាក្យខណ្ឌ គ នៃកថាខណ្ឌទី១ នៃមាត្រានេះ ការដឹកជញ្ជូនអ្នកដំណើរ និងទំនិញតាមផ្លូវគោក ផ្លូវទឹក ឬផ្លូវអាកាស គឺជាការដឹកជញ្ជូនអន្តរជាតិ ប្រសិនបើការដឹកជញ្ជូននោះត្រូវបានធ្វើឡើង៖

ក- ពីកន្លែងមួយក្នុងព្រះរាជាណាចក្រកម្ពុជា ទៅកន្លែងមួយទៀតនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

ខ- ពីកន្លែងមួយនៅក្រៅព្រះរាជាណាចក្រកម្ពុជា មកកន្លែងមួយក្នុងព្រះរាជាណាចក្រកម្ពុជា។

គ- ពីកន្លែងមួយនៅក្រៅព្រះរាជាណាចក្រកម្ពុជា ទៅកន្លែងមួយទៀតនៅក្រៅព្រះរាជាណាចក្រកម្ពុជាក្នុងករណីការដឹកជញ្ជូនឬចំណែកណាមួយនៃការដឹកជញ្ជូនឆ្លងកាត់ដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

៣- ការផ្គត់ផ្គង់ទំនិញឬសេវាដូចមានចែងក្នុងមាត្រានេះ ត្រូវមានឯកសារភស្តុតាងគ្រប់គ្រាន់ដែលអាចត្រួតពិនិត្យបាន។

## ជំពូកទី១០
## ការបញ្ឈប់និងការផ្ទេរអាជីវកម្ម

### មាត្រា៣៤ .-

បុគ្គលជាប់អាករដែលបញ្ឈប់អាជីវកម្ម ត្រូវដាក់ពាក្យស្នើសុំមករដ្ឋបាលសារពើពន្ធតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់ ក្នុងរយៈពេល ១៥ថ្ងៃ ក្រោយការបញ្ឈប់អាជីវកម្ម។ បុគ្គលជាប់អាករ ត្រូវដាក់លិខិតប្រកាសសារពើពន្ធចុងក្រោយដែលក្នុងនោះទំនិញដែលនៅសល់ក្នុងស្តុកត្រូវចាត់ទុកថា បានលក់និងត្រូវបង់ប្រាក់អាករតាមតម្លៃទីផ្សារនៅពេលបញ្ឈប់អាជីវកម្មនោះ។

### មាត្រា៣៥ .-

ការផ្ទេរអាជីវកម្មពីបុគ្គលជាប់អាករម្នាក់ទៅបុគ្គលម្នាក់ទៀតមិនត្រូវជាប់អាករលើតម្លៃបន្ថែមទេ ក្នុងករណីការផ្ទេរនោះត្រូវបានបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

១- អាជីវកម្មត្រូវបានផ្ទេរពីបុគ្គលជាប់អាករម្នាក់ទៅបុគ្គលម្នាក់ទៀត ដើម្បីបន្តធ្វើអាជីវកម្មក្រោមកម្មសិទ្ធិថ្មី។

២- បុគ្គលជាប់អាករដែលផ្ទេរអាជីវកម្មត្រូវជូនដំណឹងទៅអគ្គនាយកដ្ឋានពន្ធដារ អំពីការផ្ទេរអាជីវកម្មក្នុងរយៈពេល ១៥ថ្ងៃ ក្រោយកាលបរិច្ឆេទនៃការផ្ទេរ។

៣- បុគ្គលដែលទទួលអាជីវកម្ម ត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធនៅពេលទទួលអាជីវកម្ម និងត្រូវបន្តអនុវត្តអាករលើតម្លៃបន្ថែមចំពោះទំនិញក្នុងស្តុកនិងទ្រព្យសកម្មដែលបានទទួលនៅពេលធ្វើការផ្គត់ផ្គង់ទំនិញនិងទ្រព្យសកម្មទាំងនោះ។

៤- បុគ្គលដែលទទួលអាជីវកម្ម ត្រូវរក្សាទុកឯកសារអាករដែលទាក់ទិននឹងអាជីវកម្មដែលបានផ្ទេរនោះ ក្នុងរយៈពេល ១០ឆ្នាំ។

## ជំពូកទី១១
## អាករលើតម្លៃបន្ថែមចំពោះអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក

**មាត្រា៣៦ .-**

លក្ខខណ្ឌនៃការផ្គត់ផ្គង់ទំនិញឌីជីថលឬសេវាឌីជីថល ត្រូវបានកំណត់ដូចខាងក្រោម៖

១- ការផ្គត់ផ្គង់ទំនិញឬសេវាពីអាជីវកម្មទៅអ្នកប្រើប្រាស់ គឺជាការផ្គត់ផ្គង់ទំនិញឬសេវាពីបុគ្គលជាប់អាករទៅអ្នកប្រើប្រាស់។

២- ការផ្គត់ផ្គង់ទំនិញឬសេវាពីអាជីវកម្មទៅអាជីវកម្ម គឺជាការផ្គត់ផ្គង់ទំនិញឬសេវាពីបុគ្គលអនិវាសនជនឬបុគ្គលជាប់អាករ ទៅបុគ្គលជាប់អាករ។

**មាត្រា៣៧ .-**

បុគ្គលអនិវាសនជនដូចមានចែងក្នុងកថាខណ្ឌទី២ នៃមាត្រា៤ នៃអនុក្រឹត្យនេះ ដែលបានចុះបញ្ជីអាករលើតម្លៃបន្ថែមសាមញ្ញរួចហើយ ត្រូវមានកាតព្វកិច្ចដូចខាងក្រោម៖

១- ត្រូវប្រមូលអាករអំពីការផ្គត់ផ្គង់ទំនិញឌីជីថលឬសេវាឌីជីថលទៅឱ្យអ្នកប្រើប្រាស់ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រា៣៦ នៃអនុក្រឹត្យនេះ ហើយធ្វើការប្រកាសនិងបង់ប្រាក់អាករលើតម្លៃបន្ថែមជារៀងរាល់ខែជូនរដ្ឋបាលសារពើពន្ធតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន ដោយពុំអនុញ្ញាតនូវឥណទានអាករលើធាតុចូលទេ។

២- មិនត្រូវធ្វើការប្រមូលអាករអំពីការផ្គត់ផ្គង់ទំនិញឌីជីថលឬសេវាឌីជីថលទៅឱ្យបុគ្គលជាប់អាករដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដូចមានចែងក្នុងកថាខណ្ឌទី២ នៃមាត្រា៣៦ នៃអនុក្រឹត្យនេះទេ ប៉ុន្តែត្រូវធ្វើការប្រកាសជារៀងរាល់ខែជូនរដ្ឋបាលសារពើពន្ធ តាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន។

**មាត្រា៣៨ .-**

អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលទទួលការផ្គត់ផ្គង់ទំនិញឌីជីថលឬសេវាឌីជីថល ឬរាល់សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីបុគ្គលអនិវាសនជន ត្រូវប្រមូលអាករតាមវិធីគិតអាករជំនួស ហើយធ្វើការប្រកាសនិងបង់ប្រាក់អាករលើតម្លៃបន្ថែមជូនរដ្ឋបាលសារពើពន្ធ តាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន។

**មាត្រា៣៩ .-**

ពេលផ្គត់ផ្គង់ ត្រូវបានកំណត់ដូចខាងក្រោម៖

១- សម្រាប់បុគ្គលអនិវាសនជនដូចមានចែងក្នុងមាត្រា៣៧ នៃអនុក្រឹត្យនេះ ពេលផ្គត់ផ្គង់ គឺជាពេលមុនគេក្នុងចំណោមពេលដែលវិក្កយបត្រត្រូវបានចេញ ឬពេលទំនិញឌីជីថលត្រូវបានប្រគល់ឬសេវាឌីជីថលត្រូវបានបំពេញ ឬការទូទាត់ត្រូវបានទទួល។

២- សម្រាប់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដូចមានចែងក្នុងមាត្រា៣៨ នៃអនុក្រឹត្យនេះ ពេលផ្គត់ផ្គង់ គឺជាពេលមុនគេក្នុងចំណោមពេលដែលទំនិញឌីជីថលត្រូវបានប្រគល់ ឬសេវាឌីជីថលត្រូវបានបំពេញ ឬការទូទាត់ត្រូវដល់កំណត់ ឬបានទូទាត់។

**មាត្រា៤០ .-**

ប្រាក់អាករដែលបុគ្គលជាប់អាករបានបង់តាមវិធីគិតអាករជំនួសដូចមានចែងក្នុងមាត្រា៣៨ នៃអនុក្រឹត្យនេះ ត្រូវបានអនុញ្ញាតជាឥណទានអាករលើធាតុចូល។

**មាត្រា៤១ ._**

វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលអាករលើតម្លៃបន្ថែមលើការផ្គត់ផ្គង់ទំនិញឌីជីថលឬសេវាឌីជីថល ឬរាល់សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមកក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី១២
## អវសានប្បញ្ញត្តិ

**មាត្រា៤២ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤៣ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ២ កើត ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ